

តាំ តាំ
កំណើតភ្លើង
The History of Fire
តម្លៃ ៤០០០ រៀល

# កំណើតភ្លើង The History of fire

កាលដើមឡើយ នៅលើផែនដីគ្មានភ្លើងទេ ។ មនុស្សគ្មានអ្វីការពារខ្លួនពីភាពត្រជាក់ ហើយបរិភោគអ្វីៗឆៅទាំងអស់ គ្រាន់តែថ្ងៃលិចភ្លាម ងងឹតគ្រប់ទីកន្លែង ។ កាលនោះមនុស្សរស់នៅពិបាកណាស់ ។

Earlier, no fire was found in the earth. Humans had nothing to prevent their bodies from cold weather and always ate raw food. As soon as the sun set, it went dark everywhere. And that was the time when humans were living in genuine hardship.



មនុស្សដឹងថា នៅក្នុងដី គឺនៅបាតឋាននរក មានភ្លើងយ៉ាងច្រើន ចង់បានប៉ុន្មានក៏បានដែរ ។ ប៉ុន្តែបិសាចថែរក្សាភ្លើងនោះចាំយាមមិនឲ្យនរណាលួចបាន សូម្បីតែកូនអណ្តាតភ្លើងតូចមួយក៏មិនបានដែរ ។

Humans realized that under the earth, where the bottom of the hell was, existed as much fire as they needed, but the devil had carefully preserved it from being stolen – even a small sheet of flame could not be taken.



មនុស្សដែលសាកល្បងទៅយកភ្លើងមិនដែលឃើញត្រឡប់មកវិញទេ ។ មនុស្សក៏នាំគ្នាគិតថា : មនុស្សជាអ្នកគ្រប់គ្រងលើពិភពលោកពិតមែនតែត្រូវទទួលស្គាល់ថាសត្វមួយចំនួនអាចមានសមត្ថភាព កំលាំង ប៉ិនប្រសប់ អាចធ្វើការអ្វីៗបានសម្រេច ។

Any person who tried going for fire was never back. They thought that, "Although we're the ones who govern this earth, we have to realize that some creatures will also have capacity, strength and talent to accomplish a task."



ដូច្នេះយើងគួរបញ្ជូនសត្វឲ្យទៅឋាននរករកភ្លើងទៅក្រែង អាចយកភ្លើងបាន ។ បើយកបានយើងនឹងជូនរង្វាន់ពិសេស ដូចនេះសត្វនឹងខំប្រឹងប្រែង ។ គេក៏ប្រកាសផ្សាយគ្រប់ទីកន្លែង គ្រប់ច្រកល្ហកទាំងអស់ថា  សត្វណាដែលអាចយកភ្លើងមកផែនដីបាន នឹងអាចទៅយកចំណីអាហារ និងភេសជ្ជៈបរិភោគបានពីគ្រប់ផ្ទះរបស់មនុស្ស ។

"So, we should send creatures to the hell because they may be able to get fire. When possible, we'll award them a special present so that they'll work harder." Then the announcement was everywhere. It said if any creature was able to get fire to the earth, it would gain food and drink from every home of humans.



សត្វនោះ និងកូនចៅពូជពង្សរបស់គេអាចទៅយកចំណី អាហារ និងភេសជ្ជៈបរិភោគតាមចិត្តរហូតដល់សម័យកាលចុងក្រោយបង្អស់ ដោយមិនចាំបាច់អរគុណ ។ រង្វាន់គួរឲ្យទាក់ទាញចិត្តណាស់ ។ សត្វទាំងឡាយនាំគ្នារិះគិត ។

The successful creature and its relatives could get as much food and drink as they wished without thanks until the end of their generation. Since the award was very attractive, all creatures took it into account.



សត្វដែលក្លាហានជាងគេ សាកល្បងទៅរកភ្លើង តែត្រូវស្លាប់អស់ សត្វដែលកំសាកជាងគេនាំគ្នានិយាយថា "យើងមានទៅត្រូវការអីភ្លើងនោះ ? មនុស្សទៅរកខ្លួនឯងទៅ" ។ ល្អណាស់ ! ដែលធានាឲ្យចំណីអាហារតកូន តចៅនោះ ។ តែយើងមិនដឹងថា អាចរស់បានរហូតដល់មានកូនដែរឬទេ ?

The braver creatures gave it a try, but they were all dead. "We don't need fire!" said a coward creature. "It must be humans who go for it. It's great that they promise to give food to us and our relatives. But we're not sure if we can live until we have children."



ពេលនោះ បើសិនជាគ្មានសត្វពីងពាងទេ ប្រហែលជាយើង កំដៅខ្លួននឹងពន្លឺព្រះអាទិត្យ និងបរិភោគសាច់ឆៅតទៅទៀតក៏មិនដឹង ។ មនុស្សតែងតែអយុត្តិធម៌ចំពោះពីងពាង ។

តាមពិតសត្វពីងពាងឆ្លាត ប្រអប់ជើងរបស់វាប៉ិនប្រសប់ណាស់ ហើយជាពិសេសពីងពាងព្យាយាមអំណត់ គឺព្យាយាមខ្លាំង។

Without a spider in that time, we may have kept our bodies warm in the sunlight, or eaten raw food. Humans are always unfair to spiders.

In fact the spider is a smart creature with master legs; particularly it has great perseverance.



ពីងពាងចាប់ផ្ដើមវេញខ្សែពួរមួយឆ្មារមាំ ហើយវែងប្រវែងពីលើផ្ទៃដីទៅដល់ស្នូលផែនដី ។ ដើម្បីធ្វើខ្សែនេះបានត្រូវប្រើពេលយូរណាស់ តែពីងពាងធ្វើបាន ។ រួចពីងពាងចងចុងខ្សែនឹងផ្ទាំងថ្មដែលនៅមាត់ផ្លូវទៅឋាននរក ហើយវាទម្លាក់ខ្លួនចុះទៅក្នុងដី រហូតដល់បាតឋាននរក វាក៏ទៅពួនលាក់ខ្លួននៅក្នុងកន្លៀតមួយរង់ចាំឲ្យបិសាចបែរខ្នង ។

The spider started weaving a small, but strong web from the land surface to the earth's core. It took much time to make this rope-like web, but the spider could do it. After that, the spider tied a rock at the entrance to the hell with one end of the rope and dropped the other end to the bottom of hell. Then the spider hid at a corner until the devil stood with his back to it.



គ្រាន់តែបិសាចបែរខ្នងភ្លាម ពីងពាងក៏ស្ទុះទៅឆក់យករងើកភ្លើងមួយដុំ ហើយរត់តោងខ្សែឡើងមកវិញភ្លាម ។ ខ្សែវែងណាស់ រងើកក៏ធ្ងន់ ពីងពាងក៏ត្រូវឡើងឲ្យបានលឿនបំផុតទៀត ។ ពេលឡើងមកដល់លើដី ពីងពាងហត់ខ្លាំងណាស់ ក៏គិតថា "មនុស្សធ្លាប់អត់ភ្លើងយូរហើយ អត់បន្តិចទៀត ក៏បានដែរខ្ញុំសម្រាកសិនហើយ" ។

As soon as the devil did, the spider rushed to grasp a piece of ember, and scuttled upward on its web. Because of the long web, the heavy piece of ember and his fastest moving run, the spider arrived at the land exhausted. "Humans have had no fire for ages, and it doesn't matter if I could stay here for a brief while to take a short rest."



ពីងពាងក៏ដាក់រងើកភ្លើងចូលក្នុងក្រហូងដីមួយ ប្រះខ្លួនដេកក្បែរនោះ ហើយដេកលក់ទៅ ។ ពេលពីងពាងដេកលក់ រងើកភ្លើងក្លាយជាផេះបន្តិចម្តងៗ ពេលនោះមានរុយមួយហើរក្បែរធុំក្លិនចម្លែកដែលមិនធ្លាប់មាន គឺវាធុំក្លិនផ្សែងដែលជាផ្សែងភ្លើងទីមួយនៅលើផែនដី ។ រុយក៏ហើរទៅក្បែរដោយចង់ដឹង ហើយក៏ឃើញរងើកភ្លើងកំពុងហុយផ្សែង រីឯពីងពាងកំពុងដេកលក់ ។

The spider kept the ember in a hole on the land and took a sleep nearby. When it was asleep, the ember gradually became ash. Meanwhile, a fly coming around could smell something strange. It was the smoke from the first fire in the earth. Curious, the fly went to the site the smoke was from and discovered the ember and the sleeping spider.



រុយគិតថា "នេះជាភ្លើងដ៏មានតម្លៃនោះទេតើ ! តែពីងពាងនេះមិនចេះថែរក្សាភ្លើងទេ ទៅជាទុកចោលទៅវិញ ។ មិនល្អសោះ ។ ខ្ញុំត្រូវតែយកភ្លើងនេះទៅឲ្យមនុស្សសិន ព្រោះមនុស្សទើបចេះថែរក្សាភ្លើងនេះ ។ គិតហើយរុយក៏ឆក់យករងើកភ្លើងយកទៅឲ្យមនុស្ស ។

"That's a priceless ember!" thought the fly. "The spider is unable to preserve the ember and cast it aside. I must take this ember to humans because they know how to take care of it." Then the fly quickly took the ember to humans.



មនុស្សនិយាយថា "អរគុណហើយរុយ ! រុយបានជួយយើងខ្លាំងណាស់ ឯងនឹងបានរង្វាន់ជាទីពេញចិត្ត" ។ ចាប់ពីពេលនេះតទៅ រុយឯងនិងកូនចៅពូជពង្សឯងជារុយទាំងអស់អាចទៅបរិភោគចំណីអាហារនៅផ្ទះរបស់មនុស្សទាំងអស់ដែលរស់លើផែនដី ។ ពួករុយឯងមានសិទ្ធស៊ីផឹកតាមចិត្តរហូតដល់សម័យកាលចុងក្រោយ ដោយមិនបាច់អរគុណ ។

"Thank you!" said the human. "You've helped us a lot. You'll be given as many awards as you want. From now on, you and your relatives could go to eat food at every home of humans in the earth. Without thanks, you're allowed to eat and drink at any home of humans until the end of your generation."



ពេលពីងពាងភ្ញាក់ឡើងស្ទុះទៅរករងើកភ្លើង ដើម្បីយកទៅឲ្យមនុស្ស តែបាត់រងើកភ្លើងមិនឃើញ ។ វារត់សួរគេសួរឯង ដែលដើរកាត់កន្លែងនោះ ទើបដឹងថារុយក្លាហាន រុយមិនចេះខ្លាចបានចុះទៅឋាននរកយកភ្លើងមកឲ្យមនុស្ស ។ ពីងពាងស្រែកដោយហួសចិត្តថា "រឿងនេះមិនពិតទេ ! រុយជាចោរ ! ខ្ញុំទេ ដែលបានទៅឋាននរកយកភ្លើងមក ។ សូមមើលខ្សែរបស់ខ្ញុំដែលភ្លើងឋាននរកឆេះឡើងខ្មៅនេះជាភស្តុតាង ។

When waking up, the spider rushed to take the ember to humans, but it disappeared. The spider asked everyone who went by. Eventually, the spider discovered that the fly was brave to have brought the ember from the hell to humans. "That's not true!" yelled the spider disappointedly. "The fly is a thief. I was the one who got the ember from the hell. See my black burnt web. It is the proof."



ពីងពាងស្រែកយ៉ាងណាក៏គ្មាននរណាជឿវាដែរ ។ ឥឡូវមានភ្លើងនៅលើផែនដីទៅហើយ អ្នកណាក៏អាចដុតចុងខ្សែឲ្យខ្លោចហើយមកអួតអាងថាទើបនឹងឡើងពីឋាននរកមកបានដែរ ។ ភស្តុតាងស្អីអ៊ីចឹង ? គួរឲ្យចង់សើចណាស់ ! ពីងពាងដឹងថានិយាយទៀតក៏ឥតបានការដែរ វាក៏រកមធ្យោបាយសងសឹករុយ ។

The spider yelled loudly, but no one believed it. "Now fire exists," replied the fly, "so any one can burn a rope to prove that they've been from the hell. That's ridiculous! What a proof!" Realizing that it was nothing to insist, the spider had to do something to take its revenge on the fly.



ពីងពាងក៏ធ្វើសំបុកចងសន្ទឹងកាត់ផ្លូវរុយ ។ រុយហើរមកទាក់ជាប់ ពីងពាងស៊ីរុយភ្លាម ។ ពីមុនមកពីងពាងស៊ីតែទឹកដមផ្កាឈើទេ ។ ហើយវាចាប់ផ្ដើមស៊ីរុយពីពេលនោះរហូតមកដល់សព្វថ្ងៃ ។

The spider spun its web across the fly's way. And whenever any fly was trapped in the web, it would be at once eaten by the spider. Previously the spider ate only nectars, but it has eaten flies ever since.



ប៉ុន្តែពួកសត្វរុយនៅតែឆ្លៀតយករង្វាន់ ដែលវាលួចគេដដែល ។ រុយទៅស៊ីចំណីអាហារនៅគ្រប់ផ្ទះរបស់មនុស្សដែលរស់នៅលើផែនដី ។ សត្វរុយស៊ីផឹកតាមចិត្តនៅគ្រប់ផ្ទះ ដោយមិនបាច់អរគុណទៀតផង ។ **"ប្រហែសបាត់ ប្រយ័ត្នគង់"**

Flies, on the other hand, still take their chance of earning the stolen award. They go to eat food at every home of humans who live in the earth. Without thanks, flies eat and drink at every home.

